ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជធានីភ្នំពេញ**

**រដ្ឋបាលខណ្ឌដង្កោ**

លេខ: ១៥៧/២១ ស.ន.ណ

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការចែកបណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានខណ្ឌដង្កោ រាជធានីភ្នំពេញ

**រដ្ឋបាលខណ្ឌដង្កោ** មានកិត្តិយសសូមជម្រាបជូនដំណឹងស្ដីពីការចែកបណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ ជូនប្រជាពលរដ្ឋដែលបានមកទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ រួចហើយ និងទទួលបានសារអេឡិត្រូនិច តាមរយៈទូរស័ព្ទ ពីខាងក្រសួងការពារជាតិ តែពុំបានមកទទួលយកបណ្ណចាក់វ៉ាក់សាំងនៅឡើយ សូមអញ្ជើញមកទទួលយកបណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ នៅសាលាខណ្ឌដង្កោ ដោយឥតបង់ប្រាក់ និងសូមភ្ជាប់មកជាមួយនូវលិខិតចាក់វ៉ាក់សាំងផ្ទាល់ខ្លួន ។

សូមអញ្ជើញប្រជាពលរដ្ឋមកទំនាក់ទំនងទទួលបណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ពីក្រុមការងារចែកបណ្ណរបស់រដ្ឋបាលខណ្ឌ នៅរៀងរាល់ម៉ោងធ្វើការ ចាប់ពីម៉ោង៧:៣០ ដល់ម៉ោង១១:៣០នាទីព្រឹក និងរសៀលចាប់ម៉ោង១៤:០០ ដល់ម៉ោង៥:៣០នាទីល្ងាច ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋ អញ្ជើញមកទទួលបណ្ណចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ដោយយកចិត្តទុកដាក់អនុវត្តវិធានការ **"៣ការពារ ៣កុំ"** របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងវិធានការណែនាំនានារបស់ក្រសួងសុខាភិបាល ដើម្បីធានាបាននូវសណ្ដាប់ធ្នាប់ របៀបរៀបរយ រក្សាគម្លាតសុវត្ថិភាព ពាក់ម៉ាស ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ អោយបានគ្រប់ៗគ្នា ។

ថ្ងៃពុធ ១៤ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៦៥
ដង្កោ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២១
**អភិបាលខណ្ឌដង្កោ**

**គីម-ញឿប**

អាសយដ្ឋាន ផ្លូវ២១៧ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ Tel :(855) 088 850 77 70 E-mail: K_Dongkor@phnom penh.gov.kh